ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# កម្ពុជា ត្រូវបានអបអរសាទរ និងកោតសរសើរយ៉ាងខ្លាំង សម្រាប់ការរៀបចំយ៉ាងជោគជ័យនូវកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ

កម្ពុជាត្រូវបានអបអរសាទរ និងកោតសរសើរចំពោះការធ្វើជាម្ចាស់ផ្ទះរៀបចំប្រកបដោយជោគជ័យនូវកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ (55th AMM) និងកិច្ចប្រជុំពាក់ព័ន្ធ ពីថ្ងៃទី២៩ ខែកក្កដា ដល់ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។ ខាងក្រោមនេះ គឺជាការដកស្រង់ខ្លឹមសារចេញពីអត្ថបទ / ការវិភាគ / យោបល់ ដែលបានចុះផ្សាយក្នុងប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ៖

១. អបអរសាទរអាស៊ាន (បទវិចារណកថាដោយ Jakarta Post នៅថ្ងៃទី ៨ សីហា ២០២២)

- ថ្លែងក្នុងនាមប្រធានអាស៊ាន រដ្ឋមន្ត្រីការបរទេសកម្ពុជា ឯកឧត្តម ប្រាក់ សុខុន បានរំលឹកដល់រដ្ឋមន្ត្រីការបរទេសទាំងអស់ដែលកំពុងចូលរួមក្នុងកិច្ចប្រជុំវេទិកាតំបន់អាស៊ាន (ARF) នៅថ្ងៃសុក្រ (០៥ សីហា) ថា រដ្ឋមន្ត្រីការបរទេសទាំងអស់ត្រូវតែរក្សាឱ្យបាននូវភាពអត់ធ្មត់ សេចក្តីថ្លៃថ្នូ សុជីវធម៌ល្អ និងកិច្ចពិភាក្សាប្រកបដោយអរិយធម៌។ សារនេះគឺច្បាស់ណាស់ថា អាស៊ាន ក្នុងនាមជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ មានបុព្វសិទ្ធិដើម្បីរៀបចំបទបញ្ញត្តិមួយចំនួន ហើយអ្នកចូលរួមទាំងអស់ត្រូវតែគោរពឱ្យបានម៉ឺងម៉ាត់ មានន័យថា កុំមករញ៉េរញ៉ៃជាមួយប្រទេសជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំឱ្យសោះ !

- នៅចំកណ្តាលនៃភាពតានតឹងសកលដែលកំពុងតែកើនឡើងដោយសារតែការឈ្លានពានរបស់របស់រុស្ស៊ីទៅលើប្រទេសអ៊ុយក្រែន ក៏ដូចជា ការកើនឡើងនូវភាពតានតឹងរវាងចិន និងសហរដ្ឋអាមេរិកលើបញ្ហាកោះតៃវ៉ាន់ ពិភពលោកត្រូវការជាចាំបាច់នូវវេទិកាផ្លូវការមួយដែលយ៉ាងហោចណាស់ក៏អ្នកចូលរួម អាចសម្តែងចេញនូវជំហររបស់ខ្លួន។ ហើយអាស៊ានបានផ្តល់កន្លែងមួយដែលប្រទេសមហាអំណាចធំៗរបស់ពិភពលោកមានអារម្មណ៍ថាខ្លួនមានផាសុខភាព។ អាស៊ានជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ តែងតែព្យាយាមមិនឱ្យផុងខ្លួននៅជាប់ចំចំណុចកណ្តាលនៃការប្រយុទ្ធគ្នាដោយភៀវរបស់ខ្លួន។

- ហេតុផលមួយក្នុងចំណោមហេតុផលទាំងឡាយដែលនាំឲ្យភ្ញៀវអាស៊ានគោរពច្បាប់ល្បែងនេះ គឺដោយសារតែអាស៊ានបានទទួលជោគជ័យក្នុងការដោះស្រាយបញ្ហាផ្ទៃក្នុងដ៏លំបាក

បំផុតរបស់ខ្លួន ដោយការដាក់ទណ្ឌកម្មរបបយោធាមីយ៉ាន់ម៉ាក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ Min Aung Hlaing ចំពោះទង្វើដ៏ព្រៃផ្សៃរបស់ខ្លួន។ ជាការភ្ញាក់ផ្អើលសម្រាប់ប្រទេសជាសមាជិកមួយចំនួន សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបង្ហាញថាសម្តេចជាប្រធានអាស៊ានដែលមានការទទួលខុសត្រូវចំពោះវេទិកាតំបន់នេះ បើទោះបីជាក្នុងចិត្តរបស់សម្តេចប្រហែលជាប្រាថ្នាចង់នៅឲ្យឆ្ងាយពីកិច្ចការផ្ទៃក្នុងមីយ៉ាន់ម៉ាក៏ដោយ។

- ក្នុងនាមជាថ្នាក់ដឹកនាំមួយរូបដែលប្រកាន់ប្រជានិយម សម្តេច ហ៊ុន សែន បានទទួលស្គាល់ថា ការឈរនៅខាងមេដឹកនាំរបបយោធាដែលឃោរឃៅ អាចនឹងនាំឲ្យស្រអាប់តួនាទីរបស់សម្តេចក្នុងចំណោមមេដឹកនាំអាស៊ានតែប៉ុណ្ណោះ។ ក្នុងនាមជានាយករដ្ឋមន្ត្រីដែលកាន់អំណាចយូរជាងគេលើពិភពលោក សម្តេចក៏មានបញ្ហានៅក្នុងប្រទេសរបស់ខ្លួនផងដែរ។ ប៉ុន្តែ ដោយពុំចាប់គិតអំពីចេតនាពិតរបស់សម្តេច សម្តេច ហ៊ុន សែន ស័ក្តិសមនឹងទទួលបាននូវការទះដៃអបអរយ៉ាងកងរំពង។

- នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ដាណឺម៉ាក ក្រិក ហូឡង់ អូម៉ង់ កាតា និងអារ៉ាប់រួម បានចុះហត្ថលេខាលើលិខិតុបករណ៍នៃការចូលជាសមាជិកនៃសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ( TAC )។ ឥឡូវនេះ ប្រទេសចំនួន ៤៩ រួមទាំងសហរដ្ឋអាមេរិក ចិន ជប៉ុន បារាំង ចក្រភពអង់គ្លេស ឥណ្ឌា និងកាណាដា បានចុះហត្ថលេខាលើលិខិតុបករណ៍នៃការចូលជាសមាជិកនៃ TAC ។

- ថ្ងៃនេះគឺជាខួបអនុស្សាវរីយ៍លើកទី៥៥ របស់អាស៊ាន។ សូមអបអរសាទរអាស៊ានចំពោះវឌ្ឍនភាពដ៏គួរឱ្យចាប់អារម្មណ៍ ដែលសម្រេចបានក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងភ្នំពេញ និងរីករាយថ្ងៃកំណើតរបស់អាស៊ាន។

## ២. អាស៊ាននៅអាយុ៥៥ឆ្នាំ៖ ការរស់រានមានជីវិត និងការទទាក់ជើង

( បទវិភាគរៀបរៀងដោយ Kavi Chongkittavorn / Thai PBS World / ថ្ងៃទី០៦ សីហា ២០២២ )

- ក្នុងនាមជាប្រធានអាស៊ាននាពេលបច្ចុប្បន្ន កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនូវអ្វីដែលខ្លួនអាចធ្វើបានល្អបំផុត ដើម្បីបង្ហាញពីមជ្ឈភាព និងសាមគ្គីភាពអាស៊ាន។ លទ្ធផលនៃកិច្ចប្រជុំប្រចាំឆ្នាំរបស់អាស៊ាន គឺជាតឹកតាងបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយភាពឧស្សាហ៍ព្យាយាម។ ពិតណាស់ ប្រធានអាស៊ានបានស្តារឡើងវិញនូវភាពអាចជឿជាក់បាន ( credibility ) ដែលខ្លួនសមនឹងទទួល បន្ទាប់ពីបានសាងកំហុសកាលពីមួយទសវត្សរ៍មុន។ អាជ្ញាធរ ពាក់ព័ន្ធទាំងអស់ ជាពិសេសប្រជាជនកម្ពុជា គួរតែមានមោទនភាព។

- អាស៊ាន ក៏បានអះអាងជាថ្មីអំពីការត្រៀមខ្លួននៅក្នុងការដើរតួនាទីស្ថាបនាដើម្បីសម្របសម្រួលឱ្យមានកិច្ចសន្ទនាដោយសន្តិវិធីតាមរយៈយន្តការដឹកនាំដោយអាស៊ាន។ នៅក្នុងកិច្ចប្រជុំវេទិកាតំបន់អាស៊ាន ( ARF ) ប្រទេសជាសមាជិកទាំង ២៧ បានចែករំលែកទស្សនៈ

របស់ខ្លួនអំពីបញ្ហាប្រឈមក្នុងតំបន់ និងអន្តរជាតិ។ ការមានទស្សនៈរួម និងខុសគ្នារបស់ប្រទេសជាសមាជិក បានធ្វើឱ្យកិច្ចប្រជុំ ARF មានលក្ខណៈពិសេសប្លែកពីគេ ខណៈមហាអំណាចធំៗទាំងអស់នៅក្នុងពិភពលោកបានចូលរួម។ កាន់តែប្រសើរជាងនេះ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) ដែលបានផ្តល់លទ្ធភាពឱ្យតួអង្គក្នុងសកលលោកសំខាន់ៗ អាចជួបមុខគ្នាដោយផ្ទាល់ដើម្បីផ្លាស់ប្តូរទស្សនៈ ដោយមិនមានការប្រឈមមុខដាក់គ្នា។

៣. **កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥៖ កង្វល់ជាច្រើនដើម្បីអ្វីៗគ្រប់យ៉ាង (ឬគ្មានអ្វីទាំងអស់)** (បទវិចារណកថាដោយ Sharon Seah, Joanne Lin, Melinda Martinus / Fulcrum/ ០៨ សីហា ២០២២)

....... ទាំងនេះគឺជាចំណុចសំខាន់ៗចំនួន៦ ដែលបូកសរុបកិច្ចប្រជុំ រួមមាន៖

១. ការវិវត្តនៅច្រកសមុទ្រតៃវ៉ាន់: ការសាកល្បងថ្មីមួយអំពីភាពម៉ឺងម៉ាត់សម្រាប់អាស៊ាន

- ....... រដ្ឋមន្ត្រីការបរទេសអាស៊ាន មើលទៅហាក់បីដូចជាមិនរួញរា និងបានឆ្លើយតបយ៉ាងទាន់ពេលវេលា និងឆាប់រហ័ស តាមរយៈការចេញសេចក្តីថ្លែងការណ៍តែឯង ស្តីពី «ការវិវត្តនៅច្រកសមុទ្រតៃវ៉ាន់»។ ...... ចំពោះកេរ្តិ៍ឈ្មោះរបស់អាស៊ាន សេចក្តីថ្លែងការណ៍ដែលបានឯកភាពជាឯកច្ឆន្ទបានគ្របដណ្តប់គ្រប់ជ្រុងជ្រោយទាំងអស់ ចាប់ពីការបង្ហាញពីក្តីព្រួយបារម្ភអំពី «ការប្រែប្រួលក្នុងតំបន់» និង «ការគណនាខុសដែលអាចកើតមាន» រហូតដល់ការអំពាវនាវឱ្យមាន «ភាពអត់ធ្មត់ជាអតិបរមា» ជាដើម។ រឿងមួយដែលប្រាកដនោះគឺការអះអាងជាថ្មីយ៉ាងម៉ឺងម៉ាត់របស់ប្រទេសជាសមាជិកទាំងអស់ «គោរពគោលនយោបាយចិនតែមួយ» ។ សេចក្តីថ្លែងការណ៍នេះគឺជាសិល្បៈការទូតរបស់អាស៊ានដែលល្អបំផុត .....។

២.វិបត្តិមីយ៉ាន់ម៉ា: សម្ពាធរួមដ៏ធ្ងន់ធ្ងរ

- ការវិវត្តនានានៅក្នុងប្រទេសមីយ៉ាន់ម៉ាត្រូវបានគេរាយការណ៍ថាត្រូវបានលើកយកទៅពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងកិច្ចប្រជុំជាសេរី។ សុន្ទរកថាបើករបស់នាយករដ្ឋមន្ត្រីកម្ពុជា សម្តេច **ហ៊ុន សែន** បានផ្តល់តម្រុយអំពីទិសដៅនៃកិច្ចពិភាក្សា។ នៅក្នុងសុន្ទរកថា បានបញ្ជាក់នូវជំហរយ៉ាងម៉ឺងម៉ាត់ដ៏គួរឱ្យភ្ញាក់ផ្អើល គឺ ប្រសិនបើមានការប្រហារជីវិតអ្នកទោសនយោបាយទៀត នៅពេលនោះ អាស៊ាននឹងត្រូវបង្ខំចិត្តឱ្យធ្វើការពិចារណាឡើងវិញអំពីតួនាទីរបស់ខ្លួនពាក់ព័ន្ធនឹងការព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុចរបស់អាស៊ាន.....។

- អាស៊ានមានឯកច្ឆន្ទភាពក្នុងការសម្តែងចេញនូវការខកបំណងរបស់ខ្លួន ទៅលើវឌ្ឍនភាពតិចតួចដែលសម្រេចបានក្នុងការអនុវត្តការព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច។ សេចក្តីថ្លែងការណ៍រួមបានផ្តល់អនុសាសន៍ថា ការវាយតម្លៃអំពីវឌ្ឍនភាពក្នុងការអនុវត្តការព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុចគួរតែធ្វើឡើងនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាននៅខែវិច្ឆិកា ដើម្បី«មគ្គុទេសន៍

ឥ.

ការសម្រេចចិត្តសម្រាប់ជំហានបន្ទាប់»។ ខណៈពេលដែលមានប្រទេសជាសមាជិកមួយចំនួនទទួលយកការពន្យាពេលការសម្រេចចិត្តដោយរដ្ឋមន្ត្រីការបរទេស ទៅជាការសម្រេចចិត្តដោយថ្នាក់ដឹកនាំកំពូល វាក៏ជាការផ្តល់ឱកាស៣ខែដល់ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ (SAC) ដើម្បីបង្ហាញសុឆន្ទៈមួយចំនួនទៅដល់អាស៊ាន។ តើ «វឌ្ឍនភាព» មានរូបរាងបែបណា គឺអាស្រ័យលើការជជែកពិភាក្សាគ្នា។ គួរយល់ថា កិច្ចប្រជុំពិសេសមួយមុនកិច្ចប្រជុំកំពូលនៅខែវិច្ឆិកា ប្រហែលជាអាចត្រូវបានរៀបចំឡើងដើម្បីពិភាក្សាអំពីផ្លូវឆ្ពោះទៅអនាគត ក៏ប្រហែលជាអាចគិតឡើងវិញផងដែរអំពីអភិក្រមថ្មីចំពោះប្រទេសមីយ៉ាន់ម៉ា។

## ៣.ការចូលជាសមាជិករបស់ប្រទេសទីម័រខាងកើត: ប្រហែលជានៅឆ្នាំក្រោយ

- សំណើសុំចូលជាសមាជិកអាស៊ានរបស់ប្រទេសទីម័រខាងកើត មើលទៅឃើញថាមានការវិវត្តល្អប្រសើរ ដោយរដ្ឋមន្ត្រីការបរទេសអាស៊ានបានឯកភាព «ពន្លឿន» ដំណើរការសម្រាប់សំណើសុំចូលជាសមាជិកនេះ។ រដ្ឋមន្ត្រីការបរទេសទីម័រខាងកើត លោកជំទាវ Adaljiza Magno ត្រូវបានអញ្ជើញចូលរួមជាភ្ញៀវ និងមានជំនួបទ្វេភាគីមួយចំនួនជាមួយសមភាគីរបស់លោកជំទាវនៅក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥។ មើលលើទិដ្ឋភាពទាំងអស់នេះ កម្រាលព្រំត្រូវបានរៀបចំរួចជាស្រេចសម្រាប់ប្រទេសទីម័រខាងកើតដើម្បីចូលរួមជាមួយអាស៊ាននៅពេលដែលប្រទេសឥណ្ឌូនេស៊ីទទួលតួនាទីជាប្រធានអាស៊ាននៅឆ្នាំ២០២៣។

## ៤.ការពង្រីកទំនាក់ទំនងខាងក្រៅ៖ ការលេងល្បែងដើម្បីផលចំណេញរបស់អាស៊ាន

- អំពីបញ្ហាអ៊ុយក្រែន អាស៊ានហាក់ដូចជាបានផ្លាស់ប្តូរជំហររបស់ខ្លួនជាមួយការបើកចំហរខ្សែល្អសនៅខាងដើមចំនួនពីរដង ដោយការពារខ្លួនបានយ៉ាងល្អនៅលើផ្នែកដ៏ត្រឹមត្រូវនៃច្បាប់អន្តរជាតិ ជាអាទិ៍ «... សម្រាប់ប្រជាជាតិទាំងអស់ យើងបន្តបញ្ជាក់សារជាថ្មីនូវការគោរពរបស់យើងចំពោះអធិបតេយ្យភាព ឯករាជភាពនយោបាយ និងបូរណភាពទឹកដី» និងដោយការអះអាងជាថ្មីនូវអំពាវនាវរបស់ខ្លួនឱ្យគោរពតាមច្បាប់អន្តរជាតិ និងធម្មនុញ្ញអង្គការសហប្រជាជាតិ។ ជាថ្មីម្តងទៀត អាស៊ានបានធ្វើយ៉ាងដូច្នេះដោយមិនបានលើកដល់ប្រទេសរុស្ស៊ី។
- អំពីទំនាក់ទំនងខាងក្រៅ ប្រទេសចំនួនប្រាំមួយបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅតំបន់អាស៊ីអាគ្នេយ៍ (TAC) នៅក្នុងពិធីចុះហត្ថលេខាកាលពីថ្ងៃទី៣ ខែសីហា។ សំណើរបស់អ៊ុយក្រែនសុំចូលជាសមាជិកនៃសន្ធិសញ្ញា TAC ក៏ត្រូវបានពិចារណាផងដែរ ដោយមិនមានការជំទាស់ពីរដ្ឋមន្ត្រីការបរទេសណាម្នាក់ឡើយ (គួរកត់សម្គាល់ថា មីយ៉ាន់ម៉ាអវត្តមានពីកិច្ចប្រជុំនេះ)។ អាស៊ានបានផ្តល់ឋានៈភាពជាដៃគូសន្ទនាតាមវិស័យ (SDP) ដល់ប្រទេសប្រេស៊ីល និងអេមីរ៉ាតអារ៉ាប់រួម (ដោយចូលរួមជាមួយប្រទេសន័រវេស ប៉ាគីស្ថាន ស្វីស និងតួកគីនៅក្នុងវិស័យប្រភេទនេះ)។ អាស៊ានក៏បានរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីជាលើកដំបូងជាមួយចក្រភពអង់គ្លេស ដែលជាដៃគូសន្ទនាទី១១ របស់

អាស៊ានផងដែរ។ សំខាន់ជាងនេះទៅទៀត អាស៊ានក៏បានប្រកាសផងដែរថា ទំនាក់ទំនងដៃគូសន្ទនារបស់ខ្លួនជាមួយសហរដ្ឋអាមេរិក និងឥណ្ឌា នឹងត្រូវបានលើកកម្ពស់ទៅជា ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ នៅខែវិច្ឆិកាខាងមុខ (បន្ទាប់ពីប្រទេសចិន និងអូស្ត្រាលីកាលពីឆ្នាំមុន)។

## ៥.ភាពជាប្រធានអាស៊ានរបស់កម្ពុជា ៖ តារាងពិន្ទុពាក់កណ្ដាលអាណត្តិ

- ក្នុងនាមជាប្រធាននៃកិច្ចប្រជុំ កម្ពុជាបានដោះស្រាយទាំងខ្លឹមសារ និងថាមវន្តបានយ៉ាងល្អប្រសើរ ដោយបានរំដោះខ្លួនចេញពីការបរាជ័យកាលពីមួយទសវត្សរ៍មុនដែលខកខានក្នុងការចេញសេចក្ដីថ្លែងការណ៍រួមជាលើកដំបូងក្នុងប្រវត្តិសាស្ត្រអាស៊ាន នាឆ្នាំ២០១២ ។ កម្ពុជាមិនត្រឹមតែអាចឆ្លើយតបបានទាន់ពេលវេលាចំពោះការវិវឌ្ឍនៃស្ថានការណ៍ដែលកំពុងកើតមាននៅក្នុងរង្វង់អាស៊ានប៉ុណ្ណោះទេ កម្ពុជាថែមទាំងបានចេញសេចក្ដីថ្លែងការណ៍រួមមួយ ដែលមាន ១១៩កថាខណ្ឌ ដោយឆ្លើយតបទៅនឹងចំណុចសំខាន់ៗនៃជម្លោះ (មីយ៉ាន់ម៉ា អ៊ុយក្រែន ទស្សនៈវិស័យអាស៊ានស្ដីពីឥណ្ឌូ-ប៉ាស៊ីហ្វិក ជាដើម) បានយ៉ាងល្អនៅមុនការបញ្ចប់កិច្ចប្រជុំទាំងអស់ផងដែរ។ វាបង្ហាញអំពីកម្រិតនៃការសម្របសម្រួលដែលប្រទេសម្ចាស់ផ្ទះបានចំណាយពេល និងការប្ដេជ្ញាចិត្តរបស់ខ្លួនដើម្បីធានាថា ការចរចាលើអត្ថបទនានានឹងមិនត្រូវបានជជែកឡើងវិញនៅនាទីចុងក្រោយឡើយ។ ការសម្រេចចិត្តដើម្បីដកសេចក្ដីថ្លែងការណ៍ស្ដីពីការវិវត្តនៅច្រកសមុទ្រតៃវ៉ាន់ចេញពីសេចក្ដីថ្លែងការណ៍រួម គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវ ព្រោះវាមានហានិភ័យទៅបំផ្លាញអត្ថបទដែលបានចរចារួចហើយ។

## ៦.អំណាចកោះប្រជុំរបស់អាស៊ាន៖ ឯកភាពជាចំបង

- ថាមភាពនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានក្នុងទម្រង់កិច្ចប្រជុំទល់មុខជាលើកដំបូង ចាប់តាំងពីពេលមានជំងឺរាតត្បាតកូវីដ-១៩មក គឺមិនអាចព្យាករណ៍បាន និងមានភាពផុយស្រួយដូចជាបរិយាកាសភូមិសាស្ត្រនយោបាយ។ ភាពតានតឹងត្រូវបានគេរាយការណ៍ថា មានកម្រិតខ្ពស់នៅក្នុងកិច្ចប្រជុំចំនួន១៥ ដែលអាស៊ានធ្វើឡើងជាមួយនឹងដៃគូសន្ទនាខាងក្រៅរបស់ខ្លួន។ តួនាទីស្នូលរបស់អាស៊ាន ប្រែជាមានសភាពសើរៗនៅពេលដែលកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) បានប្រែក្លាយទៅជាវេទិកាសម្រាប់ល្បែងស្ដីបន្ទោសចោទគ្នាទៅវិញទៅមករវាងមហាអំណាចធំៗ។

- មន្ត្រីចាត់ចែងការងារក្នុងកិច្ចប្រជុំត្រូវឈឺក្បាលលើបញ្ហារៀបចំកន្លែងអង្គុយសម្រាប់រដ្ឋមន្ត្រីការបរទេសរុស្ស៊ីក្នុងកិច្ចប្រជុំ។ មានសេចក្ដីរាយការណ៍ថា ម្ចាស់ផ្ទះបានដោះស្រាយកន្លែងអង្គុយតាមបែបពិធីការនៅ EAS ដោយស្នើសុំឱ្យអនុរដ្ឋមន្ត្រីរបស់ហ្វីលីពីន Theresa Lazaro អង្គុយចន្លោះសហរដ្ឋអាមេរិក និងរុស្ស៊ី។

- គ្មានអ្វីគួរឱ្យសង្ស័យទេដែលថា អាស៊ានរក្សាអំណាចកោះប្រជុំរបស់ខ្លួនក្នុងការអញ្ជើញមហាអំណាចពិភពលោកមកកាន់តុប្រជុំ។ ប៉ុន្តែទោះជាយ៉ាងណា វានៅមិនទាន់គ្រប់គ្រាន់ក្នុងការទាក់ទាញចំណាប់អារម្មណ៍ នៅពេលនិយាយដល់នយោបាយជាក់ស្តែងរបស់ពិភពលោក។ អាស៊ានអះអាងថា អាចដើរតួនាទីសម្របសម្រួលនៅក្នុងភាពតានតឹងនៃច្រកសមុទ្រតៃវ៉ាន់ ប៉ុន្តែជាក់ស្តែង គឺការបង្កើតជំហររួមគ្នាក្នុងចំណោមសមាជិករបស់ខ្លួនចំពោះបញ្ហាក្នុងតំបន់ រួមទាំងបញ្ហាប្រទេសជិតខាងដូចជាមីយ៉ាន់ម៉ា គឺបន្តនៅតែជាបញ្ហាប្រឈម។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដ៏ល្អបំផុតរបស់អាស៊ាន (ការឯកភាពអាស៊ាន, មជ្ឈភាពអាស៊ានជាដើម) អាស៊ាននៅតែគេចមិនផុតពីការក្លាយជាចំណាប់ខ្មាំងរបស់មហាអំណាច។

៤. **ការចុះផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងតំណាងសហភាពអឺរ៉ុប ផ្តល់ចំណាត់ថ្នាក់ល្អដល់កម្ពុជាក្នុងនាមជាប្រធានអាស៊ាន** (ស្មេរ: Taing Rinith / Khmer Times / August 10, 2022)

- នៅពាក់កណ្តាលផ្លូវក្នុងតួនាទីជាប្រធានប្តូរវេនអាស៊ាន កម្ពុជាត្រូវបានគេកោតសរសើរចំពោះតួនាទី និងការរួមចំណែករបស់ខ្លួនក្នុងនាមជាប្រធានអាស៊ាន និងសម្រាប់ការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ ដោយជោគជ័យកាលពីសប្តាហ៍មុន។

- វិទ្យាស្ថាន ISEAS-Yusof Ishak ជាវិទ្យាស្ថានស្រាវជ្រាវមួយដែលពីមុនមានឈ្មោះថាវិទ្យាស្ថានសម្រាប់ការសិក្សាអំពីអាស៊ីអាគ្នេយ៍ ហើយដែលបានប្តូរឈ្មោះរបស់ខ្លួននៅក្នុងឆ្នាំ២០១៥ ដើម្បីផ្តល់ជាកិត្តិយសចំពោះប្រធានាធិបតីទី១របស់សិង្ហបុរី Yusof Ishak នោះនៅក្នុងបទវិភាគរបស់ខ្លួនដែលបានចេញផ្សាយនៅក្នុងវេទិកានយោបាយអនឡាញ Fulcrum Commentary បានកោតសរសើរកម្ពុជាចំពោះសមត្ថភាពក្នុងការដោះស្រាយភាពតានតឹងបច្ចុប្បន្នក្នុងនាមជាប្រធានអាស៊ាន ដោយផ្អែកលើលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី ៥៥ ដែលបានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញកាលពីសប្តាហ៍មុន។

- បទវិភាគសរសេរថា «ក្នុងនាមជាប្រធាននៃកិច្ចប្រជុំ កម្ពុជាបានដោះស្រាយទាំងខ្លឹមសារនិងសមត្ថភាពប្រកបដោយសក្តានុពល ដោយបានរំដោះខ្លួនចេញពីភាពបរាជ័យអស់មួយទសវត្សរ៍ ដែលខកខានចេញសេចក្តីថ្លែងការណ៍រួមជាលើកដំបូងក្នុងប្រវត្តិសាស្ត្រអាស៊ានកាលពីឆ្នាំ ២០១២ »។ (មាតិកាបន្ថែមមាននៅក្នុងចំណុចទី (៣). កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥៖ កង្វល់ជាច្រើនដើម្បីអ្វីៗគ្រប់យ៉ាង (ឬគ្មានអ្វីទាំងអស់)

- នៅក្នុងបទសម្ភាសន៍មួយជាមួយសារព័ត៌មានខ្មែរថាមស៍ កាលពីថ្ងៃសុក្រ ឯកឧត្តម ចូសេព បូរ៉េល វុនតេលេស (Josep Borrell Fontelles) តំណាងជាន់ខ្ពស់នៃសហភាពអឺរ៉ុប ទទួលបន្ទុកកិច្ចការបរទេស និងសន្តិសុខគោលនយោបាយ និងជាអនុប្រធានគណៈកម្មការអឺរ៉ុប បានផ្តល់កិត្តិយសដល់កម្ពុជាសម្រាប់គំនិតផ្តួចផ្តើមរបស់ខ្លួនក្នុងការកាត់បន្ថយអំពើហិង្សានៅមីយ៉ាន់ម៉ា បើទោះបីជាភាពជោគជ័យរបស់ខ្លួននៅមានកម្រិតក៏ដោយ។

ß.

- ឯកឧត្តម បានមានប្រសាសន៍ថា «[ក្នុងនាមជាប្រធានអាស៊ាន] កម្ពុជាកំពុងដើរតួនាទីរបស់ខ្លួនដោយការចូលរួមយ៉ាងច្រើនទាំងជាលក្ខណៈនយោបាយនិងបុគ្គល នៅក្នុងបញ្ហាមីយ៉ាន់ម៉ា»។

- «រដ្ឋមន្ត្រីការបរទេសកម្ពុជា ឯកឧត្តម ប្រាក់ សុខុន ដែលមានតួនាទីជាប្រេសិតពិសេសអាស៊ានផងនោះ បានចូលរួមយ៉ាងផុសផុលដើម្បីជំរុញឲ្យរបបសឹកយោធាឱ្យយល់ថាខ្លួនត្រូវតែផ្លាស់ប្តូរ។ ជាអកុសល កិច្ចខិតខំនេះមិនបានជោគជ័យឡើយ»។

- ឯកឧត្តម វ៉ុនតេលេស បានលើកឡើងថា ប្រទេសកម្ពុជាដែលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងគឺមិនគួរត្រូវរងការស្តីបន្ទោសណាមួយ ចំពោះបរាជ័យក្នុងការនាំមកនូវសន្តិភាពដល់ប្រទេសមីយ៉ាន់ម៉ានោះទេ។

- ឯកឧត្តមបានបន្តថា «វាមិនមែនជាកំហុសរបស់កម្ពុជានោះទេ ប៉ុន្តែវាជាកំហុសរបស់របបសឹកទៅវិញទេ»។ ការប្រហារជីវិតសកម្មជននយោបាយទាំងបួននាក់ គឺជាដំណឹងអាក្រក់បំផុតដែលយើងបានទទួលក្នុងឆ្នាំនេះ»។

- ឯកឧត្តមបានបន្ថែមថា «ខ្ញុំសូមកោតសរសើររាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ហើយខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះតួនាទីរបស់កម្ពុជាក្នុងឋានៈជាប្រធានអាស៊ានផងដែរ»។

៥. អ្នកវិភាគមើលឃើញចំណុចវិជ្ជមានជាច្រើន ពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននៅកម្ពុជា

(ស្មេរៈ <u>នៀម ឆេង</u> / ភ្នំពេញប៉ុស្តិ៍ / ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២)

- ក្រុមអ្នកវិភាគមើលឃើញចំណុចវិជ្ជមានជាច្រើនពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ (AMM-55) និងកិច្ចប្រជុំពាក់ព័ន្ធដែលរៀបចំដោយផ្ទាល់នៅកម្ពុជាជាលើកដំបូងចាប់តាំងពីមានការរាតត្បាតដោយជំងឺកូវីដ ១៩។

- រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រាក់ សុខុន បានថ្លែងថា នៅក្នុងករណីខ្លះកិច្ចប្រជុំដោយផ្ទាល់ គឺឡើងកំដៅដោយសារតែស្ថានភាពបច្ចុប្បន្ននៃកិច្ចការពិភពលោក។

- នៅក្រោយកិច្ចប្រជុំ AMM-55 នេះ មានចេញសេចក្តីថ្លែងការណ៍រួមចំនួន ២៩ទំព័រ ប៉ុន្តែនៅមុននេះបន្តិច អាស៊ានក៏បានចេញសេចក្តីថ្លែងការណ៍ដាច់ដោយឡែកស្តីពីភាពតានតឹងនៅច្រកសមុទ្រតៃវ៉ាន់ដែលកើតមានឡើងបន្ទាប់ពីដំណើរទស្សនកិច្ចរបស់ប្រធានសភាសហរដ្ឋអាមេរិកលោកស្រី ណាន់ស៊ី ប៉េឡូស៊ី ទៅកាន់កោះតៃវ៉ាន់ដែលគ្រប់គ្រងដោយខ្លួនឯង ហើយដែលប្រទេសចិនបានអះអាងជាយូរមកហើយថាជាទឹកដីរបស់ខ្លួន ក្រោមគោលនយោបាយ «ចិនតែមួយ»។

- អ្នកវិភាគ៣រូប នៅក្រុមប្រឹក្សាយោបល់ FULCRUM មានមូលដ្ឋាននៅសិង្ហបុរីនៃមជ្ឈមណ្ឌលសិក្សាអាស៊ាន ដែលជាស្ថាប័នចំណុះវិទ្យាស្ថាន ISEAS - Yusof Ishak គឺលោកស្រី

Sharon Seah លោកស្រី Joanne Lin និងលោកស្រី Melinda Martinus បានលើកឡើង ៦ចំណុចដើម្បីសង្ខេបពីកិច្ចប្រជុំនោះ រាប់ចាប់ពីដំណើរទស្សនកិច្ចរបស់ជំទាវប៉េឡូស៊ី ទៅកាន់តៃវ៉ាន់រហូតដល់បញ្ហាមីយ៉ាន់ម៉ា និងឯកភាពរបស់អាស៊ាន។ (ចំណុចទាំង៦នេះ អាចរកអានបាននៅក្នុងចំណុចទី (៣): កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន លើកទី ៥៥៖ កង្វល់ជាច្រើនដើម្បីអ្វីៗគ្រប់យ៉ាង (ឬគ្មានអ្វីទាំងអស់))

- សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងកាលសប្តាហ៍មុនថា ថ្នាក់ដឹកនាំមួយចំនួនដែលចូលរួមប្រជុំ បដិសេធអង្គុយក្បែរគូបដិបក្សរបស់ពួកគេ។ ប៉ុន្តែសម្តេចបានបន្ថែមថា អ្នកចូលរួមបានយល់ច្បាស់នូវស្ថានភាព នៅពេលដែលកម្ពុជាកំពុងធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនេះក្នុងស្ថានភាពស្មុគស្មាញមិនធ្លាប់មានពីមុនមកក្នុងនយោបាយពិភពលោក។
- សម្តេចថ្លែងថា៖ «អ៊ីចឹង សូម្បីតែការរៀបចំកៅអីអង្គុយក៏ពិបាកដែរ ព្រោះឥឡូវកំពុងតែមានជម្លោះនៅអឺរ៉ុបមានជម្លោះនៅកន្លែងមួយចំនួន។ ដូច្នេះការរៀបកៅអីអង្គុយគេមិនចង់អង្គុយជិតគ្នាក៏មាន មិនមែនជារឿងងាយស្រួលទេ»។ សម្តេចបានបន្ថែមថា ទោះបីជាយ៉ាងនេះក្តី កម្ពុជាអាចគ្រប់គ្រងធ្វើបាន។
- លោក គិន ភា ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាក៏បានមើលឃើញចំណុចល្អៗជាច្រើនចេញពីកិច្ចប្រជុំកាលពីសប្តាហ៍មុន តាំងពីការរៀបចំបដិសណ្ឋារកិច្ច និងពិធីការផ្សេងៗ ជូនឥស្សរៈជនដែលចូលរួមកិច្ចប្រជុំ។
- លោកបានមានប្រសាសន៍ថា កម្ពុជាត្រូវបានគេមើលឃើញថា មានសមត្ថភាពសម្របសម្រួលខ្ពស់ក្នុងការចាត់ចែងកិច្ចប្រជុំការទូតកម្រិតខ្ពស់ ហើយអាចចេញសេចក្តីថ្លែងការណ៍សម្រាប់កិច្ចប្រជុំនីមួយៗ ដែលមិនមែនជាកិច្ចការងាយស្រួលនោះទេ នៅក្នុងបរិយាកាសភូមិសាស្ត្រនយោបាយបច្ចុប្បន្ន។
- លោកបន្តថា៖ «កិច្ចប្រជុំនេះបានបង្ហាញជំហរច្បាស់របស់កម្ពុជាជាប្រធានអាស៊ានក្នុងការកសាងសហគមន៍អាស៊ាន និងរក្សាមជ្ឈភាពរបស់អាស៊ានដែលជាតួនាទីសំខាន់របស់ប្រធានអាស៊ាន ដោយបន្ថែមថា មុខមាត់របស់កម្ពុជាក៏ត្រូវបានលើកតម្កើងដែរ»។
- ពេលនិយាយដល់បញ្ហាតៃវ៉ាន់ លោក គិន ភា លើកឡើងថា កម្ពុជា និងអាស៊ាន បានដោះស្រាយបញ្ហាដោយភាពវៃឆ្លាត តាមរយៈការចេញថ្លែងការណ៍មួយដែលសហរដ្ឋអាមេរិក ចិន និងរុស្ស៊ីអាចទទួលយកបាន ស្របពេលបញ្ជាក់ច្បាស់អំពីផលប្រយោជន៍ស្នូលរបស់អាស៊ាន នៅក្នុងការបន្ធូរបន្ថយភាពតានតឹង និងបំណងប្រាថ្នារបស់ខ្លួនចង់ឃើញការចរចារដោយសន្តិវិធី ជាជាងជម្លោះប្រដាប់អាវុធ។

8-

៦. ក្រោយបញ្ចប់កិច្ចប្រជុំ រដ្ឋមន្ត្រីការបរទេសសិង្ហបុរី ឯកឧត្តម វីវៀន បាឡាគ្រីស្ណាន់ (Vivian Balakrishnan) បានអបអរសាទរកម្ពុជា ចំពោះជោគជ័យក្នុងការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM) **លើកទី៥៥។** (ហ្វេសប៊ុកផ្លូវការរបស់ឯកឧត្តម វីវៀន បាឡាគ្រីស្ណាន់ នៅថ្ងៃទី ០៦ សីហា ២០២២)

- រដ្ឋមន្ត្រីការបរទេសសិង្ហបុរីបានសរសេរនៅលើគណនីបណ្ដាញសង្គមផ្លូវការរបស់ឯកឧត្តមថា៖ «យើងកំពុងស្ថិតក្នុងគ្រាដ៏គ្រោះថ្នាក់មួយក្នុងទំនាក់ទំនងពិភពលោក។ ជោគជ័យនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) និងវេទិកាតំបន់អាស៊ាន (ARF) គឺជាសក្ខីភាពចំពោះតួនាទីរៀបចំប្រមូលផ្តុំរបស់អាស៊ាន ក្នុងការរក្សានិម្មាបនកម្មតំបន់ដែលបើកចំហ ប្រកបដោយបរិយាប័ន្ន និងជំរុញកិច្ចសន្ទនា និងការទូត» ។
- ឯកឧត្តមបានបន្តថា៖ «សូមអបអរសាទរចំពោះកម្ពុជាដែលបានទទួលជោគជ័យក្នុងការធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំ AMM លើកទី ៥៥» ។

៧. **រដ្ឋមន្ត្រីការបរទេសចិនកោតសរសើរកម្ពុជា សម្រាប់ការរួមចំណែកជាវិជ្ជមានដល់កិច្ចសហប្រតិបត្តិការអាស៊ីបូព៌ា** (សារព័ត៌មានខ្មែរថាមស់, នៅថ្ងៃទី ០៨ សីហា ២០២២)

- នៅក្នុងសន្និសីទកាសែតនៅល្ងាចថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២២ បន្ទាប់ពីបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ ឯកឧត្តមទីប្រឹក្សារដ្ឋ **វ៉ាង យី** បានមានប្រសាសន៍ថា កម្ពុជាបានបំពេញការងាររបស់ខ្លួនបានយ៉ាងល្អ និងជោគជ័យក្នុងការរួមចំណែកជាវិជ្ជមានដល់កិច្ចសហប្រតិបត្តិការអាស៊ីបូព៌ា។
- ឯកឧត្តមបានលើកឡើងថា៖ «យើងនឹងបន្តគាំទ្រកម្ពុជាយ៉ាងមុតមាំ។ ខ្ញុំមានជំនឿជាក់ថាកម្ពុជា នឹងបំពេញតួនាទីរបស់ខ្លួនជាប្រធានប្តូរវេនអាស៊ាន ហើយនឹងជំរុញទំនាក់ទំនងអាស៊ាន-ចិន ឈានទៅដល់កម្រិតថ្មីមួយ»។

៨. **រដ្ឋមន្ត្រីការបរទេសប៉ាគីស្ថាន** (សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងកបទ.សអ, នៅថ្ងៃទី ០៦ ខែសីហា ២០២២)

- នៅក្នុងជំនួបពិភាក្សាការងារជាមួយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២២ ឯកឧត្តមរដ្ឋមន្ត្រីការបរទេស Bilawal Bhutto Zardari បានអបអរសាទរកម្ពុជាចំពោះភាពជោគជ័យក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ។

ឲ.

៩. រដ្ឋមន្ត្រីការបរទេសទីម័រខាងកើត (សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងកបទ.សអ នៅថ្ងៃទី ០៦ ខែសីហា ២០២២)

- នៅក្នុងជំនួបទ្វេភាគីជាមួយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២២ លោកជំទាវរដ្ឋមន្ត្រីការបរទេស អាដាល់ជីហ្សា ហ្សាវីយេ រ៉េយ៍ ម៉ាកណ្ឌ បានអបអរសាទរកម្ពុជា ចំពោះភាពជោគជ័យក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ។

១០.ឯកឧត្តម អេនតូនី ប្លីនខេន (Antony Blinken) រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក បានចាកចេញពីរាជធានីភ្នំពេញដោយសុទិដ្ឋិនិយម បន្ទាប់ពីបានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន លើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

(សារព័ត៌មានខ្មែរថាមស៍, នៅថ្ងៃទី ០៧ សីហា ២០២២)

- ឯកឧត្តម អេនតូនី ប្លីនខេន បានបង្ហោះលើបណ្តាញសង្គម Twitter ថា៖ «ស្របពេលដែលខ្ញុំចាកចេញពីប្រទេសកម្ពុជា ខ្ញុំកំពុងរំលឹកឡើងវិញពីជំនួបជាមួយរដ្ឋមន្ត្រីការបរទេសអាស៊ាន និងថ្នាក់ដឹកនាំក្នុងតំបន់ដទៃទៀត។ ពួកយើងសម្រេចបាននូវវឌ្ឍនភាពឆ្ពោះទៅរកគោលដៅរួមរបស់ពួកយើង» ។

- ឯកឧត្តមបានបន្ថែមថា «ខ្ញុំចាកចេញដោយមានសុទិដ្ឋិនិយមអំពីវឌ្ឍនភាពដែលពួកយើងនៅតែអាចធ្វើបានរួមគ្នា ដើម្បីឆ្ពោះទៅរកចក្ខុវិស័យសម្រាប់តំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិករបស់ពួកយើង»។

- នៅក្នុងសន្និសីទសារព័ត៌មាន ឯកឧត្តម អេនតូនី ប្លីនខេន បានបញ្ជាក់ជាថ្មីថា សហរដ្ឋអាមេរិកនឹងបន្តមានទំនាក់ទំនងជាវិជ្ជមានជាមួយកម្ពុជា ដោយផ្អែកលើកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ដូចជាទីផ្សារនាំចេញ និងជំនួយអភិវឌ្ឍន៍។

- ក្នុងអំឡុងពេលស្នាក់នៅរាជធានីភ្នំពេញ ឯកឧត្តម ក៏បានប្រកាសអំពីគម្រោងថ្មីមួយ ដែលមានទឹកប្រាក់ចំនួន ២៥ លានដុល្លារអាមេរិក ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងកំណើនសេដ្ឋកិច្ច ក្នុងវិស័យកសិកម្មនៅកម្ពុជា ផងដែរ។

១១.សេចក្តីប្រកាសព័ត៌មានរបស់ក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន (USABC)

(ថ្ងៃទី ៧ សីហា ២០២២)

ខាងក្រោមនេះគឺជាការដកស្រង់ខ្លឹមសារចេញពីសេចក្តីប្រកាសព័ត៌មានស្តីពី ឯកឧត្តម អេនតូនី ប្លីនខេន អញ្ជើញចូលរួមក្នុងកិច្ចប្រជុំវេទិកាតំបន់អាស៊ាន ដែលចេញផ្សាយដោយ USABC ៖

- ក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន សង្ឃឹមថា ខណៈពេលសមាជិកសភា ជជែកដេញដោលអំពីច្បាប់ ដែលអាចជះឥទ្ធិពលដោយផ្ទាល់ទៅដល់អនាគត នៃទំនាក់ទំនងរវាងសហរដ្ឋ

អាមេរិក-អាស៊ាន និងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក(IPS) ដូចជាច្បាប់ស្តីពីប្រជាធិបតេយ្យនៅកម្ពុជា (Cambodia Democracy Act) ផងនោះ ក្រុមប្រឹក្សាជំរុញឱ្យមានការសន្និដ្ឋានឱ្យបានគ្រប់ជ្រុងជ្រោយជាងនេះចំពោះការដាក់ទណ្ឌកម្មសេដ្ឋកិច្ចជាឯកតោភាគីមកលើកម្ពុជាក្នុងនាមជាប្រធានអាស៊ាននាពេលបច្ចុប្បន្ន។ ការដាក់ទណ្ឌកម្ម ជាឯកតោភាគី និងការចោទប្រកាន់នេះ អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍សន្តិសុខ របស់សហរដ្ឋអាមេរិកតាមរយៈការជំរុញឱ្យកម្ពុជាកាន់តែជិតស្និទ្ធជាមួយចិន នៅពេលដែលកម្ពុជាបន្តបោះជំហានទៅរកកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ព្រមទាំងបញ្ហានិរន្តរភាពនានា ដែលមានសារៈសំខាន់ចំពោះបណ្តាក្រុមហ៊ុន និងអ្នកវិនិយោគអាមេរិក។

- បន្ទាប់ពីជំនួបរវាងរដ្ឋមន្ត្រីការបរទេសអាមេរិក ជាមួយនាយករដ្ឋមន្ត្រីកម្ពុជា ក្នុងឱកាសនៃកិច្ចប្រជុំ ARF យើងលើកទឹកចិត្តឱ្យបន្តកិច្ចសន្ទនា និងការងារកោះទូតជុំវិញបញ្ហាទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិការងារ និងការប្រើប្រាស់មូលដ្ឋានយោធាកម្ពុជារបស់ចិន ជាជាងការកំណត់ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចជាច្បាប់ ដែលអាចទទួលលទ្ធផលផ្ទុយពីការចង់បាន។

## ១២.រដ្ឋមន្ត្រីការបរទេសក្រិក

(សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងកប១.សអ, នៅថ្ងៃទី ០២ ខែសីហា ២០២២)

- នៅក្នុងជំនួបពិភាក្សាការងារជាមួយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ឯកឧត្តមរដ្ឋមន្ត្រីការបរទេស Nikos Dendias បានថ្លែងអំណរគុណចំពោះការគាំទ្ររបស់កម្ពុជា ដែលធ្វើឱ្យប្រទេសក្រិកបានចូលជាសមាជិកនៃសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (TAC) និងបានអបអរសាទរកម្ពុជាចំពោះភាពជោគជ័យនៃការធ្វើជាប្រធានអាស៊ាន។៚

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២២

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ជុំ សុន្ទរី**